**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

**សេចក្ដីប្រកាសព័ត៌មាន**
**លទ្ធផលនៃកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការបរទេសអាស៊ាន**
**ថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១ តាមរយៈប្រព័ន្ធវីដេអូ**

--------

នៅថ្ងៃទី២១ ខែមករា ឆ្នាំ២០២១ ឯកឧត្តម ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានអញ្ជើញចូលរួមកិច្ចប្រជុំចង្អៀតរដ្ឋមន្ត្រីការបរទេសអាស៊ាន ដែលបានរៀបចំឡើងតាមរយៈប្រព័ន្ធវីដេអូ។

កិច្ចប្រជុំបានសម្ដែងការគាំទ្រចំពោះមូលបទរបស់ប្រទេសប្រ៊ុយណេ "**យើងយកចិត្តទុកដាក់, យើងត្រៀមលក្ខណៈ, យើងរីកចំរើន**" និងចំណុចអាទិភាពគន្លឹះទាំងបី ដែលផ្ដោតជាសំខាន់ទៅលើការកសាងសហគមន៍មួយប្រកបដោយភាពសុខដុមរមនា ការត្រៀមលក្ខណៈនិងសម្របខ្លួនសម្រាប់ពេលអនាគតដើម្បីធានាសុខុមាលភាពប្រជាជនអាស៊ាន និងអនាគតដែលប្រកបដោយសន្តិភាព ចីរភាព និងវិបុលភាព ក៏ដូចជា ជំរុញការស្ដារឡើងវិញរបស់អាស៊ានពីជំងឺរាតត្បាតសកលកូវីដ-១៩។

ដើម្បីអនុវត្តបន្តនូវសន្ទុះនៃកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសហគមន៍អាស៊ាន ប្រ៊ុយណេបានដាក់ចេញនូវគំនិតផ្ដួចផ្ដើមមួយចំនួន ដើម្បីបង្កើតនូវនិន្នាការដែលមានលក្ខណៈយុទ្ធសាស្ត្រ ដើម្បីផ្សព្វភ្ជាប់ការឆ្លើយតបរបស់អាស៊ានទៅនឹងគ្រោះអាសន្ន និងគ្រោះមហន្តរាយនានា ក្នុងគោលបំណងដើម្បីធានាថា សហគមន៍អាស៊ានទាំងមូលកាន់តែរឹងមាំឡើង និងត្រៀមលក្ខណៈជាស្រេចសម្រាប់អនាគត។ គំនិតផ្ដួចផ្ដើមទាំងនោះរួមមាន ការបង្កើតវេទិកាដែលអាចឱ្យប្រជាជនអាស៊ានចូលរួមចំណែកដល់កិច្ចប្រឹងប្រែងបន្ធូរបន្ថយគ្រោះមហន្តរាយ លើកកម្ពស់ការប្រកាន់ភ្ជាប់នូវពហុភាគីនិយម ជំរុញការស្គាល់អត្តសញ្ញាណអាស៊ានកាន់តែខ្លាំងក្លាឡើង តាមរយៈកម្មវិធីបណ្ដុះបណ្ដាលមន្ត្រីវ័យក្មេងរបស់អាស៊ាន ក៏ដូចជា លើកកម្ពស់សកម្មភាពរបស់យុវជននៅក្នុងរបៀបវារៈសន្តិភាព និងសន្តិសុខ។

អំពីការកសាងសហគមន៍អាស៊ាន រដ្ឋមន្ត្រីការបរទេសអាស៊ាន បានពិភាក្សាពីការ[illegible]តាមដានលើបញ្ហាមួយចំនួនបន្ទាប់ពីកិច្ចប្រជុំកំពូលអាស៊ានលើកទី៣៧ នៅពេលវៀតណាមជាប្រធានអាស៊ាន ដើម្បីរក្សាសន្ទុះនៃកិច្ចខិតខំប្រឹងប្រែងក្នុងការកសាងសហគមន៍អាស៊ាន ដូចជាលទ្ធផលនៃ



អាសយដ្ឋាន: លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីមែល : mfaic@mfaic.gov.kh

ការត្រួតពិនិត្យពាក់កណ្ដាលអាណត្តិនៃការអនុម័តផែនការលំអិតសហគមន៍អាស៊ានទាំងបី ព្រមទាំងដំណើរការរៀបចំចក្ខុវិស័យសហគមន៍អាស៊ានក្រោយឆ្នាំ ២០២៥ ។ កិច្ចប្រជុំក៏បានពិភាក្សាអំពីការពន្លឿនការធ្វើសមាហរណកម្មអាស៊ាន តាមរយៈការអនុវត្តផែនការការងារនៃគំនិតផ្ដួចផ្ដើមសម្រាប់សមាហរណកម្មអាស៊ានលើកទី៤ (២០២១-២០២៥) ការអនុវត្តនូវផែនការមេស្ដីពីការតភ្ជាប់អាស៊ានឆ្នាំ២០២៥ ឲ្យបានពេញលេញ និងគាំទ្រការស្ដារឡើងវិញក្នុងតំបន់ក្រោយពីជំងឺរាតត្បាតសកល។

ចំពោះការឆ្លើយតបជាលក្ខណៈតំបន់ទៅនឹងជំងឺរាតត្បាតសកលកូវីដ-១៩ កិច្ចប្រជុំបានបង្ហាញការប្ដេជ្ញាចិត្តដើម្បីអនុវត្តក្របខណ្ឌស្ដារឡើងវិញគ្រប់ជ្រុងជ្រោយរបស់អាស៊ានឱ្យបានឆាប់រហ័ស ប្រើប្រាស់មូលនិធិសម្រាប់ការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ របស់អាស៊ាន និងធ្វើការងារឆ្ពោះទៅរកការបង្កើតក្របខណ្ឌក្នុងការរៀបចំច្រកធ្វើដំណើរក្នុងអាស៊ាន។

ចំពោះទំនាក់ទំនងជាមួយភាគីខាងក្រៅ កិច្ចប្រជុំបានសង្កត់ធ្ងន់ម្ដងទៀតពីសារៈសំខាន់នៃការពង្រឹងមជ្ឈភាពនិងឯកភាពអាស៊ាន ក្នុងទំនាក់ទំនងជាមួយដៃគូខាងក្រៅរបស់អាស៊ាន តាមរយៈយន្តការដឹកនាំដោយអាស៊ាន។ រដ្ឋមន្ត្រីការបរទេសអាស៊ានបានអបអរសាទរការចូលកាន់តំណែងរបស់រដ្ឋបាលសហរដ្ឋអាមេរិកថ្មី និងពង្រឹងពង្រឹងភាពជាដៃគូយុទ្ធសាស្ត្រអាស៊ាន-សហរដ្ឋអាមេរិក និងជំរុញកិច្ចសហប្រតិបត្តិការកំរិតខ្ពស់ ដើម្បីលើកកម្ពស់សន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាពនៅក្នុងតំបន់។ កិច្ចប្រជុំក៏បានគូសបញ្ជាក់ពីសារៈសំខាន់នៃខួបលើកទី៣០ នៃទំនាក់ទំនងដៃគូសន្ទនាអាស៊ាន-ចិន ដោយភាគីទាំងពីរធ្វើការរួមគ្នាលើគំនិតផ្ដួចផ្ដើមដើម្បីជំរុញបន្ថែមនូវទំនាក់ទំនងគ្រប់កំរិត ដើម្បីសុខុមាលភាព និងការអភិវឌ្ឍប្រកបដោយសន្តិភាពនៅក្នុងតំបន់ ។

សម្រាប់បញ្ហាក្នុងតំបន់ និងអន្តរជាតិ រដ្ឋមន្ត្រីបានចែករំលែកទស្សនៈ និងការយល់ឃើញលើបញ្ហាមួយចំនួន រួមមាន ទិដ្ឋភាពភូមិសាស្ត្រនយោបាយ ការវិវឌ្ឍនៅតំបន់ឧបទ្វីបកូរ៉េ សេដ្ឋកិច្ចពណ៌ខៀវ បញ្ហារដ្ឋរ៉ាខាញ និងបញ្ហាសមុទ្រចិនខាងត្បូង។

ក្នុងកិច្ចប្រជុំ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកឡើងនូវចំណុចមួយចំនួន ដូចខាងក្រោម៖

- ចំពោះគំនិតផ្ដួចផ្ដើមសំខាន់ៗរបស់អាស៊ានក្នុងការឆ្លើយតបជំងឺកូវីដ-១៩ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្នើថា អាស៊ានគួរតែបង្កើនចំនួនទឹកប្រាក់មូលនិធិអាស៊ានក្នុងការឆ្លើយតបទៅនឹងជំងឺកូវីដ-១៩ តាមរយៈការធ្វើទំនាក់ទំនងជាមួយវិស័យឯកជនដើម្បីចូលរួមការបរិច្ចាគ។
- សម្រាប់មជ្ឈភាពអាស៊ាន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ថា "មជ្ឈភាពអាស៊ាន" ដែលឈរលើគោលការណ៍ពិគ្រោះយោបល់និងកុងសង់ស៊ុស ការមិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង និងសិទ្ធិអធិបតេយ្យភាពស្មើភាពគ្នា គឺពិតតែសមស្របសម្រាប់អាស៊ាន នៅ

ពេលជួបជាមួយភាពបត់បែននៅក្នុងការតំរង់ទិសប្រឈមនឹងការប្រកួតប្រជែងរបស់ប្រទេសមហាអំណាច។

- ចំពោះទំនាក់ទំនងជាមួយភាគីខាងក្រៅ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់សាជាថ្មីអំពីការស្វាគមន៍របស់កម្ពុជា ចំពោះការទទួលយកចក្រភពអង់គ្លេសជាដៃគូសន្ទនារបស់អាស៊ាន និងលើកទឹកចិត្តអាស៊ានឱ្យដោះស្រាយនូវរាល់បញ្ហានីតិវិធីនានា ។
- ចំពោះបញ្ហាភាពជាដៃគូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយក្នុងតំបន់ (RCEP) **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវទំនុកចិត្តលើRCEP ថាជាចលករដ៏សំខាន់នៃការស្តារ និងធ្វើសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ហើយបានលើកទឹកចិត្តដល់ប្រទេសដែលចូលរួមក្នុង RCEP ទាំងអស់ពន្លឿនដំណើរការផ្តល់សច្ចាប័ន។
- អំពីការវិវត្តនៅឧបទ្វីបកូរ៉េ **ឯកឧត្តម** បានលើកទឹកចិត្តឲ្យមានការចូលរួមកំរិតខ្ពស់ជាមួយនឹងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ តាមរយៈវេទិកាតំបន់អាស៊ាន (ARF ) ដើម្បីបង្កើតការយោគយល់កាន់តែប្រសើរឡើង និងអាចធ្វើឱ្យមានការអភិវឌ្ឍជាវិជ្ជមាន។
- ចំពោះបញ្ហាសមុទ្រចិនខាងត្បូង កម្ពុជាចែករំលែកក្តីប្រាថ្នារួមចង់ឃើញសមុទ្រចិនខាងត្បូង ជាសមុទ្រសន្តិភាព ស្ថិរភាព កិច្ចសហប្រតិបត្តិការ និងវិបុលភាព។ កម្ពុជាតែងតែលើកទឹកចិត្តដល់ភាគីពាក់ព័ន្ធដោយផ្ទាល់ ដើម្បីដោះស្រាយភាពខុសគ្នា ប្រកបដោយការយោគយល់គ្នា តាមរយៈកិច្ចពិភាក្សាដោយសន្តិវិធី ផ្អែកលើគោលការណ៍ច្បាប់អន្តរជាតិដែលត្រូវបានទទួលស្គាល់ជាសាកល រួមទាំង អនុសញ្ញាអង្គការសហប្រជាជាតិស្តីពីច្បាប់សមុទ្រ (UNCLOS ) ឆ្នាំ ១៩៨២ ផងដែរ។ **ឯកឧត្តម**ក៏បានសង្កត់ធ្ងន់ផងដែរឱ្យបន្តកិច្ចចរចាលើក្រមប្រតិបត្តិ (COC) តាមរយៈប្រព័ន្ធវីដេអូ ដើម្បីបញ្ចប់ COC ឱ្យបានឆាប់ ដែលមានប្រសិទ្ធិភាព ប្រកបដោយខ្លឹមសារ និងស្របតាមច្បាប់អន្តរជាតិ ។
- ចំពោះបញ្ហាវេទិកាមីយ៉ាន់ម៉ា កម្ពុជាមានសេចក្តីរីករាយចំពោះវឌ្ឍនភាពដែលសម្រេចបានកន្លងមក លើការអនុវត្តអនុសាសន៍ដែលត្រូវបានធ្វើឡើងតាមរយៈការវាយតម្លៃតម្រូវការបឋម និងគាំទ្រដល់ក្រុមការងារលេខាធិការដ្ឋានអាស៊ានឱ្យបន្តចាត់វិធានការ និងតាមដានយ៉ាងយកចិត្តទុកដាក់លើបញ្ហាមនុស្សធម៌ក្នុងតំបន់នេះ៕

ថ្ងៃព្រហស្បតិ៍ ៨កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមករា ឆ្នាំ២០២១

**KINGDOM OF CAMBODIA**
**NATION RELIGION KING**

**MINISTRY OF FOREIGN AFFAIRS AND INTERNATIONAL COOPERATION**

**Press Release**
**On the Outcomes of the ASEAN Foreign Ministers' Retreat (AMM Retreat)**
21 January 2021 via Videoconference

--------

**On 21 January 2021, His Excellency PRAK Sokhonn**, Deputy Prime Minister and Minister of Foreign Affairs and International Cooperation, attended the ASEAN Foreign Ministers' Retreat (AMM Retreat) via video conference.

The Meeting expressed supports for Brunei's theme "We Care, We Prepare, We Prosper" and its three key priorities, which focus on building a harmonious ASEAN Community, preparing and adapting for the future to ensure the well-being of ASEAN people and their peaceful and sustainable prosperous future as well as advance ASEAN's recovery from the COVID-19 pandemic.

To carry forward the momentum of the ASEAN Community Building efforts, Brunei came up with a number of initiatives to form a strategic and holistic approach to link ASEAN responses to emergencies and disasters, aiming to ensure that the whole ASEAN Community is more resilient and prepared for the future. These initiatives included the establishment of a platform to enable the peoples of ASEAN to contribute to disaster relief efforts, the enhancement of upholding multilateralism, the promotion of a greater sense of ASEAN identity through ASEAN junior officials' fellowship programme as well as the promotion of the Youth in Peace and Security agenda.

On the **ASEAN Community Building**, the Ministers discussed a number of follow-up issues from the 37th ASEAN Summits under Viet Nam's ASEAN Chairmanship to keep the momentum of our Community building efforts such as the result of Mid-Term Review of the Implementation of the three ASEAN Community Blueprints, and the development process of the ASEAN Community Vision Post-2025. The Meeting also touched on acceleration of the ASEAN integration through the implementation of the IAI Work Plan IV (2021-2025), full implementation of the Master Plan on ASEAN Connectivity 2025 and support for the region's recovery from the pandemic.

On regional response to **COVID-19 pandemic**, the Meeting expressed commitment to swiftly implement the ASEAN Comprehensive Recovery Framework, utilize the ASEAN COVID-19 Response Fund, and work towards establishing the ASEAN Travel Corridor Arrangement Framework.

On the **external relations**, the Meeting re-emphasized the importance of strengthening ASEAN Centrality and Unity in the engagement with ASEAN's



Address : N° 3, Samdech HUN Sen Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia

Tel : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh

external partners through ASEAN led-mechanism. The ASEAN Foreign Ministers also congratulated the inauguration of the new U.S. Administration and looked forward to strengthen ASEAN-United States Strategic Partnership and enhance high level engagement to promote peace, security, stability and prosperity in the region. The Meeting also highlighted the significance of the 30th anniversary of ASEAN-China dialogue relations, as both sides work together on initiatives to further enhance the level of engagement for the wellbeing and peaceful development in the region.

On **regional and international development**, the Ministers shared their views and thoughts on issues such as the current regional geopolitical landscape, the development of Korean Peninsula, the Rakhine State, and the South China Sea.

In the Meeting, **His Excellency Deputy Prime Minister** raised the following points:

- On ASEAN Key Initiatives for COVID-19 Response, he suggested that ASEAN should seek to expand the ASEAN COVID-19 Response Fund by reaching out to the private sector for contribution.
- On the **ASEAN Centrality**, he emphasized that "ASEAN Way" based on consultation and consensus, non-interference and equal sovereign right have thus far served ASEAN well when it comes to the flexibility in navigating superpower rivalries.
- On the **external relations**, he reiterated that Cambodia welcomes consideration to have the United Kingdom as a Dialogue Partner of ASEAN.
- On the Regional Comprehensive Economic Partnership (RCEP) **His Excellency Deputy Prime Minister** expressed his confidence on RCEP as a key driver of regional economic recovery and integration, and encouraged all RCEP participating countries to expedite ratification process.
- On the **development in the Korean Peninsula**, he encouraged further high-level engagement with DPRK through the ASEAN Regional Forum (ARF) to create better understanding and possibly trigger positive developments
- On the **South China Sea**, Cambodia shares the common aspiration to see the South China Sea as a sea of peace, stability, cooperation and prosperity. Cambodia has always been consistent in encouraging the parties directly concerned to address differences amicably through peaceful dialogue based on universally recognized principle of international law, including UNCLOS 1982. He also emphasized the importance of the resumption of negotiations on the COC, including through a virtual means, to enable early conclusion of the COC that is effective and substantive, and consistent with international laws.
- On the **Rakhine State**, Cambodia is pleased with the progress made so far on implementation of the recommendations made by the Preliminary Needs Assessment (PNA) and supports the ASEAN secretariat task force to continue to take actions on and monitor closely this regional humanitarian issues.

Phnom Penh, 21 January 2021.